## សម្ព័ន្ធអង្គការកូសេកាំចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា




ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ នៅសាលប្រជុំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានពិធីចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការការងារ រវាងសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយការជួញដូរ(ផ្លូវភេទ)លើកុមារក្នុងប្រទេសកម្ពុជា (កូសេកាំ) ជាមួយនិងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

វត្តមានក្នុងឱកាសនោះរួមមាន ឯកឧត្តម សយ ស៊ីផុន រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច ឯកឧត្តម ម៉ក់ សូភី អនុរដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច លោក ទូន វិចិត្រ នាយកនៃសម្ព័ន្ធអង្គការកូសេកាំ រួមជាមួយមន្ត្រីរាជការក្រសួង ព្រមទាំងបុគ្គលិកសម្ព័ន្ធអង្គការកូសេកាំមួយចំនួនទៀត។

មានប្រសាសន៍ក្នុងពិធីនោះ លោក ទូន វិចិត្រ បានជម្រាបជូនខាងក្រសួងអំពីប្រវត្តិ សកម្មភាព និងសមិទ្ធផលមួយចំនួនរបស់សម្ព័ន្ធអង្គការថា សម្ព័ន្ធអង្គការកូសេកាំ បានចាប់បដិសន្ធិឡើងនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០១ ដោយមានថ្នាក់ដឹកនាំអង្គការអេដហុក គម្រោងការពារក្តីកម្ពុជា និងមជ្ឈមណ្ឌលកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ជាស្ថាបនិក។ ជាបន្តបន្ទាប់ មានអង្គការមួយចំនួនដែលធ្វើការលើបញ្ហានេះបានសុំចូលជាសមាជិក ហើយបច្ចុប្បន្នមានអង្គការចំនួន២២ជាសមាជិកសម្ព័ន្ធ។

លោក ទូន វិចិត្រ បានបញ្ជាក់បន្ថែមថា សម្ព័នអង្គការកូសេកាំ មានកម្មវិធី និងគម្រោងសំខាន់ៗចំនួនបួនគឺ កម្មវិធីតស៊ូមតិ និងស្រាវជ្រាវ កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស កម្មវិធីស្តារនីតិសម្បទា និងសមាហរណកម្ម និងគម្រោងថ្មីមួយទៀតគឺ "គម្រោងបង្កើតឲ្យមានបរិស្ថានមួយប្រកបដោយនីត្យានុកូលភាព និងនិរន្តរភាពសម្រាប់ជនត្រូវបានគេជួញដូរ ដែលអ្នកទាំងនោះកំពុងរស់នៅក្នុង និងក្រៅប្រទេសកម្ពុជា" ឬហៅកាត់ថា គម្រោងសិតកាំ "CETHCam"។ លោកបានសង្កត់ធ្ងន់ថា គម្រោងសិតកាំ ជាកម្លាំងចលករ និងយន្តការមួយដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយ និងលុបបំបាត់ការជួញដូរ និងចំណាកស្រុក ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារថ្នាក់ជាតិដើម្បីលុបបំបាត់ការជួញដូរមនុស្សនៅកម្ពុជា ដែលគម្រោងនេះមានទឹកប្រាក់ចំនួន ២៨៧៨៧៨៥ដុល្លាសហរដ្ឋអាមេរិក សម្រាប់រយៈពេលបីឆ្នាំ ចាប់ពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០១០។

លោក ទូន វិចិត្រ ក៏បានសង្កត់ធ្ងន់ដែរថា តាមរយៈពិធីចុះហត្ថលេខាលើអនុស្សារណៈនេះ បានបង្ហាញអំពីការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់រាជរដ្ឋាភិបាល ជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងគោលបំណងដើម្បីដោះស្រាយ និងលុបបំបាត់បញ្ហាជួញដូរកុមារនិងស្ត្រីកម្ពុជាឲ្យមានប្រសិទ្ធិភាព និងជោគជ័យ។

ឆ្លើយតបវិញ ឯកឧត្តម សយ ស៊ីផុន បានមានប្រសាសន៍កោតសរសើរអំពីប្រសិទ្ធភាព និងវិសាលភាពការងាររបស់សម្ព័ន្ធអង្គការកូសេកាំ ដែលឯកឧត្តមបានចាត់ទុកថាជាការងារដ៏វិសេសវិសាលក្នុងការរួមចំណែកជាមួយរដ្ឋាភិបាលដើម្បីទប់ស្កាត់ និងលុបបំបាត់ការជួញដូរកុមារក្នុងប្រទេសកម្ពុជា។ ឯកឧត្តម បានបន្ថែមថាក្រសួងក៏មិនព្រងើយកន្តើយដែរក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាក់ស្តែងក្រសួងបានកំពុងប្រឹងប្រែងពង្រឹងរចនាសម្ព័ន្ធផ្សេងៗរបស់ក្រសួងដើម្បីអនុវត្តការងារឲ្យកាន់តែមានប្រសិទ្ធភាព ហើយរាជរដ្ឋាភិបាល ក៏ដូចជាក្រសួង មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការទប់ស្កាត់ការជួញដូរមនុស្ស។ ក្រសួងក៏បានចូលរួមជាមួយក្រុមការងារថ្នាក់ជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ព្រមទាំងបានបង្កើតការិយាល័យប្រឆាំងការជួញដូរនិងសមាហរណកម្មទៀតផង។

ឯកឧត្តមបានបញ្ជាក់ទៀតថា ក្រសួងមានគោលការណ៍មួយចំនួនដើម្បីកាត់បន្ថយ និងលុបបំបាត់ការជួញដូរមនុស្សដូចជា ទប់ស្កាត់ការធ្វើចំណាកស្រុកដោយមិនមានសុវត្ថិភាព និងផ្តល់ការបណ្តុះបណ្តាលជំនាញផ្សេងៗដល់ជនងាយរងគ្រោះនិងរងគ្រោះដោយសារការជួញដូរ។ ក្រសួងក៏បានផ្តល់ដីសម្បទានសង្គមកិច្ចដល់ជនរងគ្រោះ និងជនក្រីក្រផងដែរ។

ជាថ្មីម្តងទៀត ឯកឧត្តមក៏បានកោតសរសើរដល់គ្រប់អង្គការដែលមានកម្មវិធីគាំទ្រដល់ជនរងគ្រោះដោយសារការជួញដូររហូតដល់ការធ្វើសមាហរណកម្មពួកគេទៅក្នុងសហគមន៍សមស្របមួយជាមួយនិងការងារដែលអាចចិញ្ចឹមជីវិតបាន។ ឯកឧត្តមបានជូនពរឲ្យសម្ព័ន្ធអង្គការកូសេកាំសម្រេចបាននូវបេសកកម្មរបស់ខ្លួន និងបានសង្កត់ធ្ងន់ថាជោគជ័យរបស់អង្គការក៏ជាជោគជ័យរបស់ក្រសួង និងរាជរដ្ឋាភិបាលផងដែរ។

នៅនាទីចុងក្រោយ ឯកឧត្តម សយ ស៊ីផុន និងលោក ទូន វិចិត្រ បានចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការការងាររវាងអង្គការ និងក្រសួង និងបានលើកកែវស្រាដើម្បីអបអរសាទរ។